00764193

E138/1/7/1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២

ជូនចំពោះ: សាស្ត្រាចារ្យ A.John Campbell (អ្នកជំនាញដែលអង្គជំនុំជម្រះសាលាដំបូងបានតែងតាំងដោយអនុលោមតាមដីកា E62/3)
វេជ្ជបណ្ឌិត ហួត លីនណា, វេជ្ជបណ្ឌិត កើត ឈុនលី, វេជ្ជបណ្ឌិត Seena Fazel និងវេជ្ជបណ្ឌិត Calvin Fones Soon Leng (អ្នកជំនាញដែលអង្គជំនុំជម្រះសាលាដំបូងបានតែងតាំង ដោយអនុលោមតាមដីកា E111)

ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ការិយាល័យរដ្ឋបាល

កម្មវត្ថុ: សំណើទៅអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខជំទាស់នឹងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ (ឯកសារ E138/1/7)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 01 / 2012
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

00764194

E138/1/7/1

១. កាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ កន្លងទៅ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីពេលមុននោះថា ជនជាប់ចោទពុំមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក")។ សេចក្តីសម្រេចរបស់ អ.ជ.ត.ក ដែលមានភ្ជាប់មកជាមួយនេះបានចាត់ទុកជាមោឃៈនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក និងបានបង្គាប់មកអង្គជំនុំជម្រះសាលាដំបូងដូចតទៅ៖

១) ដោយមានការពិភាក្សាជាមួយអ្នកជំនាញវេជ្ជសាស្ត្រសមស្រប ត្រូវស្នើឱ្យមានការព្យាបាលបន្ថែមដល់ជនជាប់ចោទ ដែលអាចជួយឱ្យសុខភាពផ្នែកស្មារតីរបស់ជនជាប់ចោទបានប្រសើរឡើង ដើម្បីឱ្យជនជាប់ចោទអាចមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ ហើយការព្យាបាលនេះត្រូវតែធ្វើឡើងនៅក្នុងមន្ទីរពេទ្យ ឬកន្លែងសមស្របដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្ថិតនៅក្នុងការចំណាយរបស់ អ.វ.ត.ក

២) ដោយអនុលោមតាមវិធាន ៣២ នៃវិធានផ្ទៃក្នុង ត្រូវបង្គាប់ឱ្យជនជាប់ចោទទទួលការត្រួតពិនិត្យពីអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ផ្នែកវិកលចរិត និង/ឬផ្នែកចិត្តសាស្ត្រ ដើម្បីសម្រេចថាតើជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការបានដែរឬយ៉ាងណា។ ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រនេះត្រូវធ្វើឡើងមិនឱ្យលើសពីរយៈពេល ០៦ ខែ ចាប់គិតពីថ្ងៃព្យាបាលដូចបានលើកឡើងក្នុងចំណុចទី ១ ខាងលើ

៣) ត្រូវសម្រេចដោយឥតបង្អង់ អំពីស្ថានសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការបន្ទាប់ពីទទួលបានរបាយការណ៍របស់អ្នកជំនាញ ដូចដែលបានលើកឡើងក្នុងចំណុចទី ២ ខាងលើ

៤) ត្រូវចាត់ឱ្យមានការឃុំខ្លួនជនជាប់ចោទនៅក្នុងមន្ទីរពេទ្យ ឬកន្លែងសមស្រប ដទៃទៀតក្រោមការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

៥) ត្រូវឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ននៅក្នុងមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់ពេលដែលការរៀបចំចាំបាច់នានាសម្រាប់ការព្យាបាលខាងលើ ត្រូវបានបំពេញរួចរាល់

២. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់អនុសាសន៍បន្ថែមមួយចំនួន ក្នុងនោះពាក់ព័ន្ធនឹងការពិចារណាអំពីការប្រើប្រាស់ឱសថ Donepezil បន្ទាប់ពីបានពិគ្រោះជាមួយអ្នកជំនាញវេជ្ជសាស្ត្រសមស្រប (សេចក្ដីសម្រេចរបស់ អ.ជ.ត.ក, កថាខណ្ឌ ៣៥ និង ៣៩)។ ជាងនេះទៅទៀត ត្រូវអនុវត្តការថែទាំជនជាប់ចោទនៅក្នុងបរិស្ថានដដែល ការធ្វើលំហាត់ប្រាណ កម្មវិធីជំរុញសតិបញ្ញាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ ការពិនិត្យតាមដានជាប្រចាំទៅលើសុខភាពរាងកាយជនជាប់ចោទជាទៀងទាត់ និងការវាយតម្លៃរបស់អ្នកឯកទេសព្យាបាលផ្នែកសរីរៈអំពីសកម្មភាពប្រចាំថ្ងៃរបស់ជនជាប់ចោទ និងផ្ដល់ការណែនាំអំពីការកែប្រែស្ថានភាពរស់នៅ និងវិធានការស្រដៀងគ្នា ដែលអាចបង្កផលប្រយោជន៍ដល់ជនជាប់ចោទ (កថាខណ្ឌ ៣៦)។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អ.ជ.ត.ក បានសម្រេចថា ការបន្តឃុំខ្លួនជនជាប់ចោទនៅមន្ទីរពេទ្យ ឬកន្លែងដទៃទៀត ឬមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ក្រោយពីមានការកែសម្រួលត្រឹមត្រូវ "នឹងមិនបង្កការគំរាមកំហែង ឬបញ្ហាធ្ងន់ធ្ងរណាមួយដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់ជនជាប់ចោទឡើយ"។ ជនជាប់ចោទមិនមែនស្ថិតក្នុងស្ថានភាពមួយដែល "មិនសមស្របសម្រាប់ការបន្តឃុំខ្លួននោះឡើយ" (កថាខណ្ឌ ៤២ និង កថាខណ្ឌ ៤៣)។ សេចក្ដីសម្រេច ខាងលើបានបង្គាប់ទៅការិយាល័យរដ្ឋបាលឱ្យផ្ដល់ការគាំទ្រចាំបាច់នានា នៅក្នុងការអនុវត្តសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យមានប្រសិទ្ធភាព។

៣. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសូមស្នើដល់គ្រូពេទ្យដែលព្យាបាលជនជាប់ចោទ ដោយពិគ្រោះជាមួយអ្នកជំនាញដូចដែលបានកំណត់ខាងលើ ចាប់ផ្ដើមព្យាបាលជាបន្ទាន់ដែលអាចជួយឱ្យសុខភាពផ្នែកស្មារតីរបស់ជនជាប់ចោទបានប្រសើរឡើង ដើម្បីឱ្យជនជាប់ចោទអាច

00764196

E138/1/7/1

មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ។ ការព្យាបាលនេះ ត្រូវតែស្របទៅនឹងផលប្រយោជន៍ប្រសើរបំផុតរបស់ជនជាប់ចោទ ស្របតាមក្បួនវេជ្ជសាស្ត្រ និងក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូពេទ្យ។

៤. អង្គជំនុំជម្រះសាលាដំបូងសូមធ្វើការបង្គាប់ដូចខាងក្រោមទៅអ្នកជំនាញវេជ្ជសាស្ត្រមុនៗដែលធ្លាប់បានពិនិត្យជនជាប់ចោទនាពេលកន្លងមក រួមមានដូចជា (សាស្ត្រាចារ្យ A. John Campbell (អ្នកជំនាញដែលត្រូវបានតែងតាំងដោយដីកា E62/3 របស់អង្គជំនុំជម្រះសាលាដំបូង) វេជ្ជបណ្ឌិត ហួត លីនណា, វេជ្ជបណ្ឌិត កើត ឈុនលី,វេជ្ជបណ្ឌិត Seena Fazel និងវេជ្ជបណ្ឌិត Calvin Fones Soon Leng (អ្នកជំនាញដែលត្រូវបានតែងតាំងដោយដីកា E111 របស់អង្គជំនុំជម្រះសាលាដំបូង)៖

- ផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូងដោយគ្មានការយឺតយ៉ាវនូវព័ត៌មានវេជ្ជសាស្ត្រពាក់ព័ន្ធ ដែលមានចាប់តាំងពីពេលជនជាប់ចោទ អៀង ធីរិទ្ធ បានទទួលការពិនិត្យជាលើកចុងក្រោយពីសំណាក់អ្នកជំនាញផ្នែកជំងឺផ្លូវចិត្តកាលពី ខែ កញ្ញា ឆ្នាំ ២០១១ បន្ទាប់ពីបានពិគ្រោះជាមួយវេជ្ជបណ្ឌិតព្យាបាលជនជាប់ចោទ អៀង ធីរិទ្ធ រួមទាំងការបញ្ជាក់ថាតើជនជាប់ចោទបានប្រើឱសថ Donepezil រួចហើយ ឬនៅ (ហើយប្រសិនបើជនជាប់ចោទបានប្រើប្រាស់ឱសថនេះរួចហើយ តើជនជាប់ចោទបានប្រើចាប់តាំងពីពេលណា និងមានលទ្ធផលដូចម្តេច) និងដាក់ព័ត៌មាននេះបញ្ចូលទៅក្នុងចម្លើយតបដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើ។

- ផ្តល់ព័ត៌មានមកអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង៖

  ក) ការព្យាបាល ឬការព្យាបាលជារួមដើម្បីឲ្យស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទមានភាពល្អប្រសើរ (ក្នុងគោលបំណងវាយតម្លៃឡើងវិញអំពីសម្បទាជនជាប់ចោទដើម្បីចូលរួមសវនាការ) ដែលគ្រូពេទ្យព្យាបាលជន

00764197

E138/1/7/1

ជាប់ចោទ យល់ថាសមស្រប បន្ថែមពីលើការព្យាបាលជំងឺផ្លូវកាយរបស់ជនជាប់ចោទ។

ខ) ហានិភ័យ ឬផលប្រយោជន៍ដែលបណ្តាលមកពីការព្យាបាលណាមួយ ដោយយោងទៅលើផលប្រយោជន៍ប្រសើរបំផុតរបស់ជនជាប់ចោទក្នុនវេជ្ជសាស្ត្រ ក្រមសីលធម៌ ដូចមានចែងនៅក្នុងក្រមសីលធម៌គ្រូពេទ្យកម្ពុជា។

គ) តើការព្យាបាលគួរបន្តធ្វើរយៈពេលប៉ុន្មាន រហូតដល់មានការវាយតម្លៃឡើងវិញអំពីស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទ និង/ឬ ស្ថានភាពសុខភាពទូទៅត្រង់ចំណុចពាក់ព័ន្ធនឹងបញ្ហាសម្បទាជនជាប់ចោទ ដើម្បីចូលរួមសវនាការ។

ឃ) បញ្ហាពាក់ព័ន្ធនានានៅក្នុងឋានៈវិជ្ជាជីវៈជាអ្នកជំនាញ

- ដើម្បីសម្រួលកិច្ចការឲ្យបានទាន់តាមពេលវេលាកំណត់ អង្គជំនុំជម្រះសូមស្នើថាអ្នកជំនាញទាំងអស់គួរចាត់តាំងអ្នកជំនាញមួយរូបជាតំណាងឲ្យអ្នកជំនាញទាំង ៥ រូប ដើម្បីឆ្លើយតបទៅនឹងសំណើនេះ ឬខ្លួនគួររៀបចំផែនការការងារប្រហាក់ប្រហែលនេះ។

- អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យអ្នកជំនាញតំណាង ជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ថាតើការផ្លាស់ប្តូរទីកន្លែងឃុំខ្លួនជនជាប់ចោទនាពេលបច្ចុប្បន្ន មានប្រយោជន៍វេជ្ជសាស្ត្រអតិបរមាដល់ជនជាប់ចោទដែរឬទេ ប្រសិនបើការកែលំអស្ថានភាពមន្ទីរឃុំឃាំងមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ព្យាបាលជនជាប់ចោទទេនោះ។

00764198

E138/1/7/1

- ជារៀងរាល់ ២ សប្ដាហ៍ម្ដង អ្នកជំនាញតំណាងត្រូវធ្វើបច្ចុប្បន្នភាពជូនអង្គជំនុំជម្រះសាលាដំបូងស្ដីអំពីដំណើរវិវឌ្ឍន៍ និងលទ្ធផលនៃការព្យាបាលណាមួយដើម្បីធ្វើឱ្យស្ថានភាពបញ្ហាស្មារតីរបស់ជនជាប់ចោទមានភាពល្អប្រសើរ។

៥. តាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ការិយាល័យរដ្ឋបាលត្រូវដើរតួនាទីជាចំណុចបង្គោលរវាងអ្នកជំនាញ អង្គជំនុំជម្រះ និងបុគ្គលពាក់ព័ន្ធផ្សេងៗ និងត្រូវផ្ញើអនុសាសន៍របស់អ្នកជំនាញមកអង្គជំនុំជម្រះសាលាដំបូងនៅពេលខ្លួនបានទទួល។ អនុសាសន៍របស់អ្នកជំនាញគួរត្រូវបានប្រគល់ទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងអំឡុងរយៈពេល២សប្ដាហ៍គិតចាប់ពីថ្ងៃស្នើសុំ អាស្រ័យទៅតាមការវាយតម្លៃបន្ថែមពីសំណាក់អ្នកជំនាញផ្នែកជំងឺផ្លូវចិត្ត ឬអ្នកជំនាញព្យាបាលរោគមនុស្សចាស់ (តាមការចាំបាច់)។ នេះជាសំណើបន្ទាន់ ដោយហេតុថាសំណើនេះពាក់ព័ន្ធនឹងបញ្ហាឃុំខ្លួនជនជាប់ចោទនាពេលបច្ចុប្បន្ន។

៦. ក្នុងករណីចាំបាច់ត្រូវអនុវត្តតាមសេចក្ដីបង្គាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យអ្នកជំនាញធ្វើការពិគ្រោះជាមួយជនជាប់ចោទ និងក្រុមគ្រួសាររបស់ជនជាប់ចោទ ក៏ដូចជាបុគ្គលិកនៃមន្ទីរឃុំឃាំង អ.វ.ត.ក (រួមទាំងគ្រូពេទ្យព្យាបាលជនជាប់ចោទផង)។ តាមការស្នើ-សុំការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ត្រូវប្រគល់ឱ្យអ្នកជំនាញនូវឯកសារវេជ្ជសាស្ត្រទាំងឡាយដែលពួកគេត្រូវការចាំបាច់ សម្រាប់ផ្ដល់អនុសាសន៍ជូនអង្គជំនុំជម្រះសាលាដំបូង។

៧. អង្គជំនុំជម្រះសាលាដំបូងសូមយកឱកាសនេះ ដើម្បីបញ្ជាក់អំពីមូលដ្ឋាននៃការឃុំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ នាពេលបច្ចុប្បន្ន។ ដោយអនុលោមតាមសេចក្ដីសម្រេចរបស់ អ.ជ.ត.ក ដីកាដើមរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានចាត់ទុកជាមោឃៈ (សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ផ្នែកសម្រេចសេចក្ដី)។ អ.ជ.ត.ក បានយល់ឃើញទៀតថាមូលដ្ឋានដំបូងក្នុងការឃុំខ្លួនជនជាប់ចោទ (ការធានាវត្តមានជនជាប់ចោទក្នុងអំឡុងកិច្ចដំណើរការនីតិវិធី) នៅតែមានសុពលភាពគតិយុត្ត (កថាខណ្ឌ៤១, ៤៨)។ អ.ជ.ត.ក ក៏បានគូសបញ្ជាក់ថា "ពាក់ព័ន្ធនឹងការបន្តឃុំខ្លួនជនជាប់ចោទ បញ្ហានេះស្ថិតក្រោមការពិនិត្យមើលឡើងវិញដោយអនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង ស្របតាម

គោលការណ៍ទូទៅ" (កថាខណ្ឌ ៤៩)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ថា ត្រូវបន្តឃុំខ្លួនជនជាប់ចោទ រហូតដល់ពេលមានការវាយតម្លៃឡើងវិញអំពីសម្បទាជនជាប់ចោទដើម្បីចូលរួមសវនាការ ដោយអនុលោមតាមសេចក្តីសម្រេចរបស់ អ.ជ.ត.ក។ ជាងនេះទៅទៀត នៅពេលមានការស្នើសុំ អង្គជំនុំជម្រះសាលាដំបូងអាចពិនិត្យមើលឡើងវិញអំពីមូលដ្ឋាននៃការឃុំខ្លួនជនជាប់ចោទ ឬអំពីកំហិតផ្សេងៗទៅលើសេរីភាពរបស់ជនជាប់ចោទ ដោយអនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង។

ឯកសារភ្ជាប់